THE Coca-Cola COMPANY

# គោលនយោបាយ
# **សិទ្ធិមនុស្ស**
# សកល

ខែធ្នូ ឆ្នាំ 2023

## សិទ្ធិមនុស្ស និងក្រុមហ៊ុនរបស់យើង

ការគោរព សិទ្ធិមនុស្សគឺមានសារៈសំខាន់ណាស់សម្រាប់ ក្រុមហ៊ុនកូកា-កូឡា។ វាកំណត់ទំនាក់ទំនងរបស់យើងជាមួយនិយោជិត ការរំពឹងទុកចំពោះអ្នកផ្គត់ផ្គង់ និងក្រុមហ៊ុនដៃគូផលិត ព្រមទាំងការចូលរួមរបស់យើងជាមួយសហគមន៍ និងអតិថិជន។ យើងជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនដំបូងគេដែលប្រកាន់យកគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ព្រោះវាស្របតាមក្រមសីលធម៌សាជីវកម្ម បេសកកម្ម និងចក្ខុវិស័យរបស់យើង។ យើងជាក្រុមហ៊ុនសកល ហើយយើងខិតខំធ្វើឱ្យជីវិត កាន់តែប្រសើរឡើង។

គោលនយោបាយស្តីពីសិទ្ធិមនុស្សរបស់យើងឆ្លុះបញ្ចាំងពីតម្លៃរបស់យើង ហើយនឹងបន្តជាត្រីវិស័យ ក្នុងគោលនយោបាយសិទ្ធិមនុស្ស។ គោលនយោបាយនេះអនុវត្តចំពោះក្រុមហ៊ុនកូកា-កូឡា អង្គភាពនានាដែលយើងជាម្ចាស់ អង្គភាពដែលយើងមានហ៊ុនភាគច្រើន និងអង្គភាពដែលយើងគ្រប់គ្រង។ យើងក៏រំពឹងថាក្រុមហ៊ុនដៃគូផលិត និងអ្នកផ្គត់ផ្គង់ឯករាជ្យរបស់យើងនឹងគោរពតាមស្តង់ដារសិទ្ធិមនុស្សស្របតាមគោលការណ៍ណែនាំសម្រាប់អ្នកផ្គត់ផ្គង់របស់យើង។

---

## ការប្តេជ្ញាចិត្តរបស់យើង

យើងប្តេជ្ញាចំពោះគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស និងគោលការណ៍ណែនាំរបស់ OECD សម្រាប់សហគ្រាសពហុជាតិនៅទូទាំងប្រតិបត្តិការអាជីវកម្ម និងខ្សែសង្វាក់ផលិតកម្ម របស់យើង។ យើងគោរពសិទ្ធិមនុស្សទាំងអស់ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ដែលមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ អនុសញ្ញាស្នូលរបស់អង្គការពលកម្មអន្តរជាតិ និងសេចក្តីប្រកាសរបស់ ILO ស្តីពីគោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ។

យើងមានទំនួលខុសត្រូវខ្ពស់ ចំពោះភាគីពាក់ព័ន្ធដែលងាយរងគ្រោះបំផុត រួមមានសហគមន៍ជនជាតិភាគតិច ស្ត្រី កម្មករចំណាកស្រុក និងកុមារ ក្នុងក្រុមផ្សេងៗទៀត ។ យើងខិតខំដើម្បីកំណត់អត្តសញ្ញាណ និងដោះស្រាយហានិភ័យសិទ្ធិមនុស្សសំខាន់ៗនៅទូទាំងប្រតិបត្តិការ និងខ្សែចង្វាក់ផលិតកម្ម របស់យើង។ យើងធ្វើការស៊ើបអង្កេត និងចូលរួមជាមួយភាគីពាក់ព័ន្ធដើម្បីការពារ និងកាត់បន្ថយហានិភ័យ។ យើងផ្តល់ និងសហការក្នុងការទទួលបានដំណោះស្រាយក្នុងករណីសមស្រប។

# សិទ្ធិខាងក្រោមគឺជាមូលដ្ឋានគ្រឹះនៃកម្មវិធីសកលរបស់យើង៖

## កន្លែងធ្វើការមានសុវត្ថិភាព និងសុខភាពល្អ

កម្មករមានសិទ្ធិទទួលបានកន្លែងធ្វើការប្រកបដោយសន្តិសុខ សុវត្ថិភាព និងផាសុខភាព។ នៅក្នុងប្រតិបត្តិការផ្ទាល់របស់យើង យើងធ្វើការដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ របួស និងការប៉ះពាល់ទៅនឹងហានិភ័យសុខភាព។ យើងមិនអត់ឱនចំពោះការបៀតបៀន រួមទាំងពាក្យសម្តី ផ្លូវកាយ ផ្លូវភេទ ឬការប្រព្រឹត្តផ្សេងៗទៀត ដែល បង្កើតបរិយាកាសការងារដែលគួរឱ្យភ័យខ្លាច ឬអរិភាពឡើយ។

## ភាពចម្រុះ និងការបញ្ចូល

កម្មករទាំងអស់មានសិទ្ធិទទួលបាននូវសេចក្តីថ្លៃថ្នូរនិងការគោរពស្មើៗគ្នា។ យើងធ្វើការយ៉ាងសកម្មដើម្បីលើកកម្ពស់កន្លែងការងារចម្រុះ សមភាព និងរួមបញ្ចូលដោយមិនមានការរើសអើងលើមូលដ្ឋាននៃពូជសាសន៍ ភេទ ពណ៌សម្បុរ សញ្ជាតិ ឬសង្គម ជាតិសាសន៍ សាសនា អាយុ ពិការភាព ស្ថានភាពសុខភាព ទំនោរផ្លូវភេទ ស្ថានភាពអាពាហ៍ពិពាហ៍ ការមានផ្ទៃពោះ អត្តសញ្ញាណយេនឌ័រ ឬការបញ្ចេញមតិ មតិនយោបាយ ឬក្រុមផ្សេងទៀតដែលត្រូវបានការពារ  នៅក្រោមច្បាប់ជាធរមាន។

## សេរីភាពនៃសមាគម

កម្មករនិយោជិតមានសិទ្ធិចូលរួម ឬបង្កើតសហជីពដោយមិនភ័យខ្លាចការសងសឹក ការបំភិតបំភ័យ អំពើហិង្សា ឬការយាយី។ នៅពេលច្បាប់ក្នុងស្រុកដាក់កម្រិតខ្លាំងពេកនូវសេរីភាពក្នុងការបង្កើតសមាគម យើងគាំទ្រវេទិកាវិធីផ្សេងៗ ដើម្បីបើកការសន្ទនារបស់កម្មកររួម និងមានការចូលរួមជាមួយគណៈគ្រប់គ្រង។

## សេរីភាពពីពលកម្មដោយបង្ខំ

យើងហាមប្រាមរាល់ការប្រើប្រាស់ពលកម្មដោយបង្ខំ រួមទាំងការងារក្នុងពន្ធនាគារ ការងារជាប់កិច្ចសន្យា ការងារពេលជាប់ឃុំ ពលកម្មយោធា ពលកម្មទាសករ ឬទម្រង់នៃការជួញដូរមនុស្ស។ ល័ក្ខខ័ណ្ឌការងារ ត្រូវតែមានភាពស្មោះត្រង់ និងច្បាស់លាស់ ជាភាសាដែលកម្មករនិយោជិតម្នាក់ៗយល់។ គ្មាននរណាម្នាក់អាចនឹងត្រូវបង្ខិតបង្ខំ ឬបោកបញ្ឆោត តម្រូវឱ្យបង់ថ្លៃសេវា ឬតម្រូវអោយប្រគល់ឯកសារផ្ទាល់ខ្លួន ដើម្បីទទួលបានការងារនោះទេ។

THE Coca-Cola COMPANY

## សេរីភាពពីពលកម្មកុមារ

យើងហាមប្រាមការជួលកុមារដែលមានអាយុក្រោម 15 ឆ្នាំ ឬក្រោមអាយុស្របច្បាប់នៃការងារ ឬការសិក្សាជាកាតព្វកិច្ច យើងគោរពច្បាប់ស្តីពីសេរីភាពពីពលកម្មកុមារណាដែលមានតឹងរឹងជាង ។ ការលើកលែងណាមួយត្រូវតែស្របច្បាប់ និងស្របតាមនិយមន័យនៃ "ការងារស្រាលៗ" ដែលអនុញ្ញាតនៅក្រោមមាត្រ 7 នៃ ILO 138។ យើងហាមប្រាមការជួលមនុស្សដែលមានអាយុក្រោម 18 ឆ្នាំដើម្បីចូលរួមក្នុងការងារដែល ILO ចាត់ទុកថាមានគ្រោះថ្នាក់។ យើងផ្ទៀងផ្ទាត់អាយុរបស់និយោជិតទាំងអស់នៅពេលពួកគេត្រូវបានជួល។

## ប្រាក់ឈ្នួល និងម៉ោងធ្វើការ

កម្មករនិយោជិតត្រូវតែទទួលបានសំណងដោយស្មើភាពដោយអនុលោមតាមច្បាប់ជាតិ ស្តង់ដារឧស្សាហកម្ម និងទីផ្សារការងារក្នុងស្រុក និងស្របតាមកិច្ចព្រមព្រៀងចរចារួម ។ រាល់ការងារបន្ថែមម៉ោងត្រូវបានបង់ក្នុងបុព្វលាភដែលសមស្រប ហើយកម្មករទាំងអស់មានសិទ្ធិទទួលបានរយៈពេលសម្រាកសមរម្យ និងថ្ងៃសម្រាក។

## សិទ្ធិលើដីធ្លី

យើងគោរពសិទ្ធិកម្មសិទ្ធិស្របច្បាប់ និងប្រពៃណីរបស់សហគមន៍។ យើងមិនអត់ឱនចំពោះការទន្ទ្រានយកដី ហើយប្រជាជនក្នុងសហគមន៍ជន ត្រូវតែទទួលបានព័ត៌មានគ្រប់គ្រាន់ និងពិគ្រោះយោបល់ឱ្យបានត្រឹមត្រូវក្នុងដំណើរការទិញដី ស្របតាមគោលការណ៍នៃការយល់ព្រមដោយសេរី ជូណដំណឹងជាមុន និងការផ្តល់ព័ត៌មាន។

## ភ្នាក់ងារគ្រប់គ្រងទឹក និងបរិស្ថាន

យើងយកគោលការណ៍សិទ្ធិមនុស្សជាវិធីសាស្រ្ត មូលដ្ឋានលើ ការកាត់បន្ថយហានិភ័យ និងការវាយតម្លៃពីហានិភ័យទឹកក្នុងតំបន់ ការពិគ្រោះយោបល់ និងសហការណ៍ជាដៃគូជាមួយរដ្ឋាភិបាល សហគមន៍ និងភ្នាក់ងារពាក់ព័ន្ធដទៃទៀតដើម្បីបង្កើតដំណោះស្រាយសំពាធ/បញ្ហាទឹក នៅពេលចាំបាច់ ហើយក៏បានអនុវត្តផែនការការពារ ប្រភពទឹក ផងដែរ។ យើងធ្វើការយ៉ាងសកម្មដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងកាត់បន្ថយ ឧស្ម័នកាបូនិករបស់យើងតាមរយៈការកំណាត់គោលដៅដែលផ្អែកលើវិទ្យាសាស្រ្ត។ យើងក៏ជួយលើកកម្ពស់ និងការពារជម្រកធម្មជាតិ តំបន់ការពារ និងជីវចម្រុះ រួមទាំង ស្វែងរកវិធីសាស្រ្តដែលបង្កើតភាពធន់នឹងការប៉ះទង្គិច និងភាពតានតឹងនៃអាកាសធាតុរយៈពេលវែង។

## ឯកជនភាព

យើងគោរពសិទ្ធិឯកជនភាពរបស់បុគ្គល និងអនុវត្តការការពារសមរម្យ ដើម្បីការពារព័ត៌មានផ្ទាល់ខ្លួន និងសម្ងាត់ដែលយើងត្រូវបានប្រគល់ឱ្យ ស្របតាមគោលនយោបាយស្ដីពីឯកជនភាពរបស់យើង។ យើងផ្ដល់មធ្យោបាយសមរម្យដើម្បីចែករំលែកសំណួរ ឬការសង្កេត ដែលជួយយើងក្នុងការបន្តពង្រឹងវិធីសាស្ត្រនៃការ ការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនប្រកបដោយការពិចារណា និងត្រឹមត្រូវ។

## សុខមាលភាពអ្នកប្រើប្រាស់

ការប្ដេជ្ញាចិត្តរបស់យើងចំពោះសិទ្ធិមនុស្ស ពាក់ពន្ធទៅដល់អតិថិជន និងអ្នកប្រើប្រាស់របស់យើង។ យើងប្ដេជ្ញាចិត្តធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម ប្រកបដោយទំនួលខុសត្រូវ និងការផ្ដល់នូវព័ត៌មានអាហារូបត្ថម្ភប្រកបដោយតម្លាភាព ព្រមទាំងផ្ដល់នូវជម្រើសភេសជ្ជៈជាច្រើនដែលអាចឱ្យអ្នកប្រើប្រាស់ធ្វើការជ្រើសរើសប្រកបដោយការយល់ដឹង ស្របតាមរបៀបរស់នៅដែលមានផាសុខភាព។

---

## អភិបាលកិច្ច និងការអនុវត្ត

គោលនយោបាយនេះត្រូវបានត្រួតពិនិត្យដោយអនុប្រធានជាន់ខ្ពស់ ផ្នែកសិទ្ធិមនុស្សសកល ផ្នែកទំនាក់ទំនងការងារ និងនិយោជិត ដែលរាយការណ៍ជាទៀងទាត់ទៅកាន់នាយកប្រតិបត្តិ និងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។ នាយកដ្ឋានសិទ្ធិមនុស្សសកល (GHR) ដឹកនាំយុទ្ធសាស្ត្រ និងកម្មវិធីសិទ្ធិមនុស្សរបស់ក្រុមហ៊ុន ដោយផ្ដល់ព័ត៌មានថ្មីៗជាប្រចាំដល់ក្រុមប្រឹក្សាភិបាលអំពីហានិភ័យ ការអនុវត្ត និងការរំពឹងទុកនៃការវិវត្តនៅទូទាំងខ្សែសង្វាក់ផលិតកម្មជាសកលរបស់យើង។

GHR ធ្វើការនៅទូទាំងក្រុមហ៊ុន ដើម្បីបង្កើតគោលនយោបាយ និងការអនុវត្តការពារសិទ្ធិមនុស្ស ដែរមានការចូលរួមជាមួយភាគីពាក់ព័ន្ធ ព្រមទាំងធ្វើការបណ្ដុះបណ្ដាលស្ដីពីគោលនយោបាយសិទ្ធិមនុស្ស។ GHR ក៏មើលការខុសត្រូវលើការអនុវត្តគោលការណ៍ណែនាំអ្នកផ្គត់ផ្គង់របស់យើង ដែលបង្ហាញពីការរំពឹងទុកអំពីការគោរពគោលនយោបាយសិទ្ធិមនុស្សរបស់ក្រុមហ៊ុន ចំពោះក្រុមហ៊ុនដៃគូផលិត និងអ្នកផ្គត់ផ្គង់ឯករាជ្យ ការត្រួតពិនិត្យ និងរាយការណ៍អំពីប្រសិទ្ធភាពនៃការអនុវត្តធៀបនឹងគោលដៅ ប្រចាំឆ្នាំ។

គោលនយោបាយស្ដីពីសិទ្ធិមនុស្សសកល

## ការរំពឹងទុករបស់អ្នកផ្គត់ផ្គង់ និងក្រុមហ៊ុនដៃគូផលិត

សេចក្តីណែនាំរបស់យើងសម្រាប់អ្នកផ្គត់ផ្គង់ត្រូវបានចុះកិច្ចសន្យា និងអនុវត្តតាមរយៈ គោលការណ៍ណែនាំអ្នកផ្គត់ផ្គង់របស់យើង និង គោលការណ៍សម្រាប់កសិកម្មដែលមាននិរន្តរភាព។ យើងធ្វើតំហែទាំនូវកម្មវិធីយ៉ាងម៉ត់ចត់ដើម្បីធានាថាអ្នកផ្គត់ផ្គង់ និងក្រុមហ៊ុនច្រកដបបំពេញបានតាមតម្រូវការសិទ្ធិមនុស្សទាំងនេះ។ យើងធ្វើការជាមួយក្រុមហ៊ុនដៃគូផលិត និងអ្នកផ្គត់ផ្គង់ ដើម្បីជួយពួកគេដោះស្រាយបញ្ហា ប្រឈមទាក់ទងនឹងសិទ្ធិមនុស្ស និងការដោះស្រាយការខូចខាត ប៉ុន្តែយើងនឹងបញ្ចប់ទំនាក់ទំនងរបស់អ្នកផ្គត់ផ្គង់ជុំវិញបញ្ហាសិទ្ធិមនុស្ស នៅពេលសមស្រប។

## ការចូលរួមរបស់ភាគីពាក់ព័ន្ធ

យើងចូលរួមជាទៀងទាត់ជាមួយសហគមន៍ កម្មករ អ្នកការពារសិទ្ធិមនុស្ស និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីធានាថាទស្សនៈរបស់ពួកគេត្រូវបានជូនដំណឹងដល់ក្រុមហ៊ុនមុនការសម្រេចចិត្តរបស់យើង ហើយក្រុមហ៊ុនអាចចាត់វិធានការសមហេតុផលទាំងឡាយដើម្បីការពារអ្នកការពារសិទ្ធិមនុស្ស និងអ្នកពាក់ព័ន្ធផ្សេងទៀតពីការប្រើ អំពើហិង្សាលើ ការបំភិតបំភ័យ ឬការសងសឹកផ្សេងទៀត។ យើងចាត់ទុកទំនាក់ទំនងទាំងនោះមានសារៈសំខាន់ចំពោះភាពជោគជ័យរបស់យើង និងការចូលរួមជាគោលការណ៍របស់យើងជាមួយពិភពលោក។

## ការតវ៉ា និងដំណោះស្រាយ

ដោយអនុលោមតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស យើងធ្វើការដើម្បីធានាឱ្យមានលទ្ធភាពទទួលបានដំណោះស្រាយសមស្របសម្រាប់អ្នកទាំងឡាយណាដែលទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សដែលទាក់ទងនឹងប្រតិបត្តិការរបស់យើង។ បណ្តាញក្រុមសីលធម៌ KO អនុញ្ញាតឱ្យនរណាម្នាក់—មិនថានិយោជិត បុគ្គលិកកម្មករនៅក្នុងខ្សែចង្វាក់ផលិតកម្ម សមាជិកនៃសហគមន៍ដែលរងផលប៉ះពាល់ ឬមនុស្សផ្សេងទៀត—ដើម្បីរាយការណ៍អំពីបញ្ហាសិទ្ធិមនុស្ស ឬក្រុមសីលធម៌ផ្សេងៗ។ វាអាចចូលប្រើបានតាមអនឡាញ និងតាមរយៈទូរសព្ទជា 23 ភាសា។ ពាក្យបណ្តឹង និងសារទុក្ខអាចរាយការណ៍ដោយអនាមិក។ យើងស៊ើបអង្កេត និងចាត់វិធានការកែតម្រូវសមស្រប ដើម្បីឆ្លើយតបទៅនឹងការបំពានណាមួយ។ យើងមិនដែលដាក់លក្ខខណ្ឌក្នុងការប្រើបណ្តាញក្រុមសីលធម៌ និង ការលះបង់សិទ្ធិផ្លូវច្បាប់របស់អ្នកតវ៉ាឡើយ។

ក្រុមហ៊ុនសូមរក្សាសិទ្ធិកែប្រែគោលនយោបាយនេះគ្រប់ពេល។ ការអនុលោមតាមគោលនយោបាយនេះមិនមែនជាការធានាលើការបន្តការងារជាមួយក្រុមហ៊ុនកូកា-កូឡា នោះទេ។

គោលនយោបាយស្តីពីសិទ្ធិមនុស្សសកល